# ផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុក

ដោយសារតែមានការកើនឡើងនូវការធ្វើចំណាកស្រុកក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទើបអង្គការយូនីសេហ្វបានរៀបចំឱ្យមានការសិក្សានេះឡើង ដើម្បីវាយតម្លៃលើផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុក។ ការស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម៖

- វាយតម្លៃលើផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុក ទាក់ទិននឹងកិច្ចការពារកុមារ ទំនាក់ទំនងក្នុងរង្វង់គ្រួសារ ការទទួលបានសេវាអប់រំ សុខភាព និងសេវាផ្សេងទៀត។ ការសិក្សានេះផ្តោតការយកចិត្តទុកដាក់លើកុមារដែលត្រូវឪពុកម្តាយទុកចោលផង និងកុមារដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយផង។

- ពិនិត្យមើលអន្តរាគមន៍ដែលមានស្រាប់ ដែលអនុវត្តដោយរាជរដ្ឋាភិបាលផង និងអង្គការមិនមែនរដ្ឋាភិបាលផង ដែលផ្តល់ប្រយោជន៍ដល់កុមារដែលមានឪពុកម្តាយជាជនចំណាកស្រុក។

- ផ្តល់អនុសាសន៍អំពីសកម្មភាព ដែលគួរអនុវត្តដោយរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាដោយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

ការស្រាវជ្រាវនេះ គឺជាការស្រាវជ្រាវបែបគុណវិស័យ ដែលមានគោលបំណងបង្ហាញឱ្យឃើញពីនិន្នាការ បច្ចុប្បន្ន បញ្ហា សេវាដែលមាន និងសេវាដែលនៅខ្វះខាត សម្រាប់កុមារដែលរងផលប៉ះពាល់ដោយសារការធ្វើចំណាកស្រុក។ ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើង ដើម្បីផ្តល់ព័ត៌មានស៊ីជម្រៅអំពីផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុក តាមរយៈការសន្ទនាដោយផ្ទាល់ជាមួយក្រុមគោលដៅ និងការពិនិត្យឡើងវិញលើឯកសារពាក់ព័ន្ធនានា ក៏ដូចជាលើទិន្នន័យបរិមាណវិស័យ ដែលមានស្រាប់អំពីការធ្វើចំណាកស្រុក។



ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើងតាមរយៈការពិភាក្សាក្រុមគោលដៅ (FGDs) ចំនួន ២៩ ជាមួយនឹងអ្នកចូលរួមចំនួន ២៥១ នាក់ (ក្នុងនោះមានមនុស្សពេញវ័យ ៦២ នាក់ ជាឪពុកម្តាយ អាណាព្យាបាល និងជីដូនជីតារស់នៅតាមភូមិ និងកុមារ ១៨៩ នាក់ ដែលធ្វើចំណាកស្រុកតាមឪពុកម្តាយផង និងត្រូវបានឪពុកម្តាយទុកចោលក្នុងភូមិផង) ហើយការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានធ្វើឡើងក្នុងទីក្រុងភ្នំពេញ និងខេត្តគោលដៅ (ខេត្តបាត់ដំបង ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង និងខេត្តសៀមរាប)។

# ទំហំនៃការធ្វើចំណាកស្រុក

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការធ្វើចំណាកស្រុកក្នុងប្រទេស និងទៅក្រៅប្រទេសមានការកើនឡើង ក្នុងប្រទេសកម្ពុជា។

ស្របពេលដែលប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចក្នុងអត្រាមួយថេរ ក្នុងទសវត្សរ៍ចុងក្រោយនេះ កំណើនការងារកើតឡើងតែក្នុងឧស្សាហកម្មមួយចំនួនតូចប៉ុណ្ណោះ ដូចជា វិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ជាដើម។ កំណើនការងារក្នុងវិស័យទាំងនេះជាទូទៅ កើតឡើងជុំវិញរាជធានីភ្នំពេញ ដែលនាំឱ្យមានការកើនឡើងនូវការធ្វើចំណាកស្រុកក្នុងប្រទេស ដោយយុវជន ប្តីប្រពន្ធ និងគ្រួសារដែលមានកូន ត្រូវចាកចេញពីភូមិកំណើតរបស់ខ្លួន ហើយផ្លាស់ទីទៅកាន់កន្លែងដែលពួកគេអាចរកការងារធ្វើបាន។

របាយការណ៍នៃគម្រោងចំណាកស្រុកពីជនបទទៅទីក្រុងនៅកម្ពុជា (CRUMP) សន្និដ្ឋានថា ចំនួនប្រជាជនក្នុងទីក្រុងភ្នំពេញបានកើនឡើងទ្វេដងពីឆ្នាំ ១៩៩៨ ដល់ ២០០៨ ពោលគឺពី ៥៦៧.៨៦០ នាក់ ដល់ ១.២៣៧.៦០០ នាក់ ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំប្រមាណជា ៨%។

ប្រជាជនកម្ពុជាបានធ្វើចំណាកស្រុកទៅកាន់ប្រទេសជិតខាង ដើម្បីស្វែងរកការងារធ្វើផងដែរ។ ជាមួយនឹងនិន្នាការបែបនេះ គេចាំបាច់ត្រូវរៀបចំគោលនយោបាយ ដែលបង្កភាពងាយស្រួលដល់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្តល់ការការពារដល់សិទ្ធិរបស់ពលករចំណាកស្រុកឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ គោលដៅចម្បងសម្រាប់ពលករខ្មែរ គឺប្រទេសកូរ៉េខាងត្បូង ម៉ាឡេស៊ី និងថៃ (TAF, 2011)។ រាជរដ្ឋាភិបាលកម្ពុជាកាន់តែផ្តល់ការគាំទ្រដល់ការធ្វើចំណាកស្រុកទៅក្រៅប្រទេស។

ទោះជាយ៉ាងនេះក្តី ទិន្នន័យអំពីកុមារដែលរងផលប៉ះពាល់ដោយសារការធ្វើចំណាកស្រុក ក្នុងស្រុកក្តី ឬទៅក្រៅប្រទេសក្តី មានតិចតួចបំផុត។ បច្ចុប្បន្ននេះ ពុំមានស្ថាប័នរដ្ឋាភិបាល ឬទីភ្នាក់ងារអន្តរជាតិណាក្នុងប្រទេសកម្ពុជា ដែលធ្វើការប្រមូលទិន្នន័យបរិមាណវិស័យក្នុងលក្ខណៈជាប្រព័ន្ធអំពីកុមារចំណាកស្រុក ឬកុមារដែលមានឪពុកម្តាយជាជនចំណាកស្រុកឡើយ។

ការអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា (CIPS) ឆ្នាំ ២០១៣ បានធ្វើការប្រមូលទិន្នន័យពីកុមារចំណាកស្រុក ប៉ុន្តែពុំបានបញ្ចូលកុមារអាយុក្រោម ១០ ឆ្នាំ ក្នុងការវិភាគទិន្នន័យ និងរបាយការណ៍ឡើយ។ បើតាមរបាយការណ៍នៃការអង្កេតនេះ ក្នុងចំណោមជនចំណាកស្រុកទាំងអស់ដែលគេប៉ាន់ប្រមាណក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ២០១៣ មាន ៨,៣% មានអាយុចន្លោះពី ១០ ទៅ ១៩ ឆ្នាំ ក្នុងនោះអាយុចន្លោះពី ១០ ដល់ ១៤ ឆ្នាំ មាន ៣,២% និងអាយុ ១៦-១៩ ឆ្នាំ មាន ៥,១%។

ក្នុងឆ្នាំ ២០១១-២០១២ ក្រសួងផែនការបានធ្វើការសិក្សាជាលើកដំបូងលើការធ្វើចំណាកស្រុកក្នុងប្រទេសនៅកម្ពុជា ក្រោមគម្រោងចំណាកស្រុកពីជនបទទៅទីក្រុងនៅកម្ពុជា (CRUMP)។ បច្ចុប្បន្ន គម្រោង CRUMP គឺជាការសិក្សាគ្រប់ជ្រុងជ្រោយជាងគេអំពីការធ្វើចំណាកស្រុកក្នុងប្រទេសនៅកម្ពុជា ដោយមានបង្ហាញពីច្រកផ្លូវដែលគេប្រើប្រាស់ញឹកញាប់ជាងគេ សាវតាររបស់ជនចំណាកស្រុក និងមានការវិភាគខ្លះពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកលើសហគមន៍ ប្រភពដើមរបស់ជនចំណាកស្រុក។

ប៉ុន្តែ ទិន្នន័យស្តីពីកុមារមានតិចតួចបំផុត។ ការសិក្សារបស់គម្រោង CRUMP បង្ហាញថា ជនចំណាកស្រុកនៅតំបន់ជនបទ ច្រើនមានកូនតិចជាងអ្នកដែលមិនធ្វើចំណាកស្រុក។ ស្ត្រីចំណាកស្រុកដែលរៀបការហើយ ទំនងជាមិនមានកូន៖ ស្ត្រីចំណាកស្រុករៀបការហើយ ៣០,១% ក្នុងសំណាកគំរូនេះ ពុំមានកូនឡើយ បើធៀបជាមួយនឹងតួលេខត្រឹមតែ ៥,៩% នៃស្ត្រីរៀបការហើយដែលមិនធ្វើចំណាកស្រុក។ ជនចំណាកស្រុកដែលរៀបការហើយ ក៏មិនទំនងជាមានកូនច្រើននាក់នោះដែរ។ មានជនចំណាកស្រុកត្រឹមតែ ១៩%ប៉ុណ្ណោះ ដែលមានកូនចាប់ពី ៣ នាក់ឡើងទៅ ធៀបជាមួយនឹងតួលេខ ៦៣% នៃអ្នកដែលមិនធ្វើចំណាកស្រុកក្នុងតំបន់ជនបទ។ ជារួម ទិន្នន័យរបស់គម្រោង CRUMP បង្ហាញថា ប្រជាជនកម្ពុជាដែលធ្វើចំណាកស្រុកច្រើនតែជាអ្នកដែល

មិនបានរៀបការ ហើយពុំមានកូន ឬមានកូនតិច បើធៀបជាមួយនឹងប្រជាពលរដ្ឋផ្សេងទៀត។

ព័ត៌មានបន្ថែមអំពីចំនួនជនចំណាកស្រុកក្នុងគ្រួសារកម្ពុជា អាចរកបានពីមូលដ្ឋានទិន្នន័យឃុំសង្កាត់។ ទិន្នន័យនេះគឺប្រមូលដោយមេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ និងមន្ទីរផែនការ។ សំណុំទិន្នន័យនេះបង្ហាញដោយសង្ខេបពីចំនួនប៉ាន់ប្រមាណនៃអ្នកធ្វើចំណាកស្រុកចេញក្រៅ ដើម្បីគោលបំណងសេដ្ឋកិច្ច ដែលមានអាយុលើសពី ១៨ ឆ្នាំ តាមឃុំនីមួយៗក្នុងប្រទេស ដោយមានការបែងចែកតាមយេនឌ័រ។

ខុសពីការអង្កេតចន្លោះជំរឿន មានតែសមាជិកគ្រួសារ ដែលមុខរបរចម្បងគឺ "ធ្វើចំណាកស្រុកស្វែងរកការងារធ្វើ" ប៉ុណ្ណោះ ដែលត្រូវបានកត់ត្រាក្នុងសំណុំទិន្នន័យនេះ។ សំណុំទិន្នន័យនេះពុំបានធ្វើការបែងចែកប្រភេទនៃការធ្វើចំណាកស្រុក (រយៈពេលវែង រយៈពេលខ្លី ឬតាមរដូវឡើយ)។ មូលដ្ឋានទិន្នន័យ ឃុំសង្កាត់ ពុំបានប្រមូលព័ត៌មានអំពីកូនរបស់ជនចំណាកស្រុក ឬកុមារដែលធ្វើចំណាកស្រុកឡើយ។

ទោះជាយ៉ាងណាក៏ដោយ គេនៅតែអាចប្រើប្រាស់មូលដ្ឋានទិន្នន័យឃុំសង្កាត់ (CDB) ដើម្បីកំណត់រកសហគមន៍ ដែលមានអត្រាមនុស្សពេញវ័យធ្វើចំណាកស្រុកចេញក្រៅដើម្បីគោលបំណងសេដ្ឋកិច្ចខ្ពស់ជាងគេ។ ឧទាហរណ៍ សម្រាប់ខេត្តប្រភពដើមដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ តួលេខក្នុងឆ្នាំ ២០១៤ ត្រូវបានបង្ហាញក្នុងតារាងទី ១ (ភាគរយ គឺជាភាគរយជនចំណាកស្រុកធៀបនឹងចំនួនប្រជាជនសរុបក្នុងខេត្ត)៖



**តារាងទី ១៖ ភាគរយនៃជនចំណាកស្រុកធៀបនឹងចំនួនប្រជាជនសរុបក្នុងខេត្ត (CDB ២០១៤)**

| ខេត្តប្រភពដើម | ចំនួនប្រជាជនសរុបក្នុងខេត្ត | ក្នុងប្រទេស | | | ទៅក្រៅប្រទេស | | | ចំនួនជនចំណាកស្រុកសរុប (% ក្នុងខេត្ត) |
|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | |
| ព្រៃវែង | 1.194.146 | 52.481 | 55.548 | 108,029 (9%) | 32.588 | 17.060 | 49.648 (4,2%) | 157.677 (13,2%) |
| បាត់ដំបង | 1.173.414 | 28.580 | 20.378 | 48.958 (4,2%) | 50.219 | 34.174 | 84.393 (7.2%) | 133.351 (11,4%) |
| សៀមរាប | 1.042.286 | 13.328 | 10.036 | 23.364 (2,2%) | 32,794 | 20,411 | 5.205 (5.1%) | 76.569 (7,3%) |

តារាងនេះបង្ហាញថាខេត្តព្រៃវែងបញ្ជូនជនចំណាកស្រុកទៅខេត្តផ្សេងក្នុងប្រទេស ក្នុងចំនួនច្រើនជាងជនចំណាកស្រុកទៅក្រៅប្រទេសដល់ទៅពីរដង ដែលត្រូវគ្នានឹងទិន្នន័យរបស់គម្រោង CRUMP ដែរ ដោយគម្រោងនេះបានរកឃើញថា ខេត្តព្រៃវែង គឺជាខេត្តមួយក្នុងចំណោមខេត្តប្រភពដើមធំៗជាងគេ នៃជនចំណាកស្រុកទៅកាន់រាជធានីភ្នំពេញកាលពីពេលថ្មីៗនេះ(CRUMP 2012)។ ខេត្តបាត់ដំបង និងខេត្តសៀមរាប ទំនងជាខេត្តប្រភពដើមនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយសារតែខេត្តទាំងពីរនេះនៅជិតប្រទេសថៃ។ ប៉ុន្តែ ខុសពីគម្រោង CRUMP ទិន្នន័យ CDB ពុំបានផ្តល់ព័ត៌មានអំពីចំនួនកុមារចំណាកស្រុក ដែលឪពុកម្តាយយកទៅតាម ឬទុកចោល ឬចំនួនកុមារដែលធ្វើចំណាកស្រុកខ្លួនឯង (អាយុក្រោម ១៨ ឆ្នាំ) នោះទេ។

របាយការណ៍នគរបាលជាតិបង្ហាញតួលេខប្រជាជន ដែលផ្លាស់ទីចេញពីភូមិកំណើតរបស់ខ្លួន ជារៀងរាល់ខែ។ របាយការណ៍នេះក្តោបលើចំនួនមនុស្សដែលចាកចេញពីភូមិកំណើតដើម្បីរកការងារធ្វើ ហើយក៏ផ្តល់ព័ត៌មានអំពីការធ្វើចំណាកស្រុករបស់កុមារផងដែរ។ ទិន្នន័យនេះគឺប្រមូលបានពីប៉ុស្តិ៍នគរបាលទូទាំងប្រទេស និងបូកសរុបនៅថ្នាក់ជាតិ នឹងអាចរកបាននៅគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សផងដែរ។ បើតាមប្រភពព័ត៌មាននេះ ការធ្វើចំណាកស្រុកមានការកើនឡើងជិតពីរដង ចាប់ពីឆ្នាំ ២០១៤ ដល់ ២០១៥។ របាយការណ៍បានបង្ហាញថា មានមនុស្សចំនួន ៤៥០.៨៤៥ នាក់ធ្វើចំណាកស្រុក/ចាកចេញពីភូមិ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៥ បើធៀបជាមួយនឹង ២៤១.៣៧៥ នាក់ ក្នុងខែដដែល កាលពីឆ្នាំ ២០១៤។

តាមរយៈការធ្វើការងារជាមួយនឹងសមភាគីថៃ ក្នុងការគ្រប់គ្រងជនចំណាកស្រុក រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលព័ត៌មានអំពីការធ្វើចំណាកស្រុកនេះផងដែរ។ ឧទាហរណ៍ បើតាមជំរឿនដែលធ្វើឡើង ដោយរដ្ឋាភិបាលថៃ កាលពីខែ មីនា ឆ្នាំ ២០១៥ មានជនចំណាកស្រុកជាង ៤៥០.០០០ នាក់ ដែលធ្វើការងារខុសច្បាប់ ក្នុងប្រទេសថៃ។

ជារួម មានយន្តការ សម្រាប់ប្រមូលព័ត៌មានអំពីការផ្លាស់ទីរបស់ប្រជាជនឬការធ្វើចំណាកស្រុក ប៉ុន្តែគុណភាពទិន្នន័យនៅមានកម្រិតនៅឡើយ។ មានការរកឃើញភាពខុសគ្នាគួរឱ្យកត់សម្គាល់ជាមួយនឹងទិន្នន័យដែលបានពីប្រភពផ្សេងៗ។ យន្តការទាំងនេះមានដូចជាការប្រមូលទិន្នន័យរដ្ឋបាល (មូលដ្ឋានទិន្នន័យឃុំ របាយការណ៍ប្រចាំខែរបស់នគរបាលស្តីពីការផ្លាស់ទីរបស់ជនចំណាកស្រុក និងការផ្លោះប្តូរព័ត៌មានរវាងប្រទេសនិងប្រទេស) និងទិន្នន័យដែលបានពីការអង្កេតនានា ដូចជា ការអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា និងគម្រោងចំណាកស្រុកពីជនបទទៅទីក្រុង ជាដើម។

# មូលហេតុនៃការធ្វើចំណាកស្រុក

ការស្រាវជ្រាវបឋមនៃការសិក្សានេះបានបញ្ជាក់ថា ហេតុផលធំជាងគេដែលនាំឱ្យគ្រួសារធ្វើចំណាកស្រុកគឺហេតុផលហិរញ្ញវត្ថុ។ ការរកឃើញនេះគឺដូចគ្នានឹងលទ្ធផលនៃការអង្កេតរបស់គម្រោង CRUMP ដែរ ដែលបានរកឃើញថាហេតុផលធំជាងគេនៃការធ្វើចំណាកស្រុកគឺពាក់ព័ន្ធជាមួយនឹងការងារ (៨៥% នៃជនចំណាកស្រុកទៅទីក្រុងភ្នំពេញ និង ៩៧ នៃជនចំណាកស្រុកទៅក្រៅប្រទេស)។ ការស្រាវជ្រាវដល់ទីតាំងផ្ទាល់ តាមរយៈករណីសិក្សាផ្សេងៗ បានពិនិត្យលំអិតលើកត្តានានាដែលនាំឱ្យមានការធ្វើចំណាកស្រុក។ ក្នុងចំណោមករណីសិក្សាចំនួន ៧ មានករណីសិក្សាចំនួន ៦ បង្ហាញពីនិន្នាការស្រដៀងៗគ្នា។ ក្នុងករណីសិក្សាទាំងនេះមានសមាជិកគ្រួសារម្នាក់ធ្លាក់ខ្លួនឈឺ។ គ្រួសារប្រើប្រាស់ដីជាវត្ថុបញ្ចាំដើម្បីខ្ចីលុយគេមករ៉ាប់រងថ្លៃព្យាបាល រួមនឹងថ្លៃធ្វើដំណើរទៅកាន់មន្ទីរពេទ្យផង។ ក្នុងករណីភាគច្រើន គ្រួសារខ្ចីលុយពីអ្នកចងការប្រាក់ និងពីគ្រឹះស្ថានផ្តល់កម្ចីនានា ដោយជារឿយៗ ពួកគេខ្ចីពីម្ចាស់បំណុលមួយដើម្បីទៅសងម្ចាស់បំណុលមួយទៀត។ ក្នុងករណីសិក្សាទាំង ៦ ប្រាក់កម្ចីមានការកើនឡើង ហើយគ្រួសារជំពាក់គេចន្លោះពី ១.០០០ ទៅ ១០.០០០ ដុល្លារ ក្នុងពេលដែលមានការស្រាវជ្រាវនេះ។ ប្រឈមជាមួយនឹងការបាត់បង់ដីធ្លីផងនោះ គ្រួសារទាំងនេះបានសម្រេចចិត្តបញ្ជូនកូនជាយុវជនដល់អាយុធ្វើការភាគច្រើនទៅប្រទេសថៃដើម្បីធ្វើការងារតាមការដ្ឋានសំណង់។ មានគ្រួសារតែមួយគត់ក្នុងករណីសិក្សាទាំងនេះ ដែលពុំបានធ្វើចំណាកស្រុក ដើម្បីសងបំណុល ហើយក្នុងករណីសិក្សានេះ គ្រួសារធ្វើចំណាកស្រុកដើម្បីសន្សំប្រាក់សម្រាប់រៀបអាពាហ៍ពិពាហ៍។



# តើកុមារនៅ ឬទៅ

ប្រទេសកម្ពុជា គឺជាហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមាត្រា ១២ ចែងថា គួរមានការពិចារណាលើទស្សនៈរបស់កុមារពាក់ព័ន្ធនឹងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវិត និងសុខុមាលភាពរបស់ពួកគេ។ ចំណុចនេះរាប់បញ្ចូលការសម្រេចចិត្តធ្វើចំណាកស្រុករបស់ឪពុកម្តាយផងដែរ។ ប៉ុន្តែ ការឆ្លើយតបភាគច្រើនលើសលុបរបស់កុមារ និងមនុស្សពេញវ័យដែលត្រូវបានសម្ភាស ក្នុងការសិក្សានេះ បានរកឃើញថា ពុំមានការពិគ្រោះយោបល់ជាមួយកុមារឡើយនៅពេលដែលឪពុកម្តាយរបស់ពួកគេសម្រេចចិត្តធ្វើចំណាកស្រុក មិនថាកុមារមានអាយុប៉ុន្មាន ឬរស់នៅទីណាឡើយ។ ក្នុងករណីភាគច្រើន គេគ្រាន់តែប្រាប់កុមារក្រោយពេលមានការសម្រេចចិត្តរួច ហើយជាទូទៅ កុមារពុំមានឥទ្ធិពលលើការសម្រេចចិត្តនេះឡើយ។ ក្នុងសំណាកគំរូដែលមានកុមារ ១៨៩ នាក់របស់យើង មានកុមារតែ ២ នាក់ប៉ុណ្ណោះ ដែលឪពុកម្តាយបានសួរនាំថាតើពួកគេចង់នៅ ឬចង់ទៅជាមួយពួកគេ។

ករណីសិក្សាក្នុងការស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា ការសម្រេចចិត្តនេះទទួលរងឥទ្ធិពលដោយសារកត្តាមានសមាជិកគ្រួសារដែលអាចមើលថែកុមារបាន ឬអត់។ ឪពុកម្តាយធ្វើចំណាកស្រុក ដែលពុំមានសមាជិកគ្រួសារ ជាធម្មតាគឺជីដូន ឬជីតាអាចមើលថែកុមារបាន មានជម្រើសតិចតួចប៉ុណ្ណោះ ក្រៅតែពីយកកុមារទៅតាម។

ជម្រើសមួយក្នុងចំណោមជម្រើសទាំងនេះគឺមណ្ឌលថែទាំកុមារ។ ការសិក្សាមួយកន្លងមកបានរកឃើញទំនាក់ទំនងរវាងការធ្វើចំណាកស្រុក និងការយកកុមារទៅដាក់តាមមណ្ឌលក្នុងប្រទេសកម្ពុជា (Jordanwood, 2011)។ ក្នុងករណីមួយចំនួន ឪពុកម្តាយរាយការណ៍ថាយកកូនទៅដាក់តាមមណ្ឌលថែទាំ ដើម្បីឱ្យខ្លួនអាចធ្វើចំណាកស្រុកបាន។ ខណៈពេលការរស់នៅតាមមណ្ឌលថែទាំអាចឱ្យកុមារទទួលបានការអប់រំ ការរស់នៅបែបនេះក៏មានផលប៉ះពាល់ជាអវិជ្ជមានជាច្រើនមកលើការអភិវឌ្ឍកុមារផងដែរ (Jordanwood, 2011)។

# ផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុក

គិតរហូតមកដល់ពេលថ្មីៗនេះ ការស្រាវជ្រាវភាគច្រើនផ្តោតលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ដែលការធ្វើចំណាកស្រុកមានដោយផ្ទាល់លើសេដ្ឋកិច្ចរបស់គ្រួសារនីមួយៗ និងលើប្រទេស ឬពិនិត្យលើផលវិបាក ចេញពីជ្រុងនៃនគូបនីយកម្ម។ ការស្រាវជ្រាវចុងក្រោយបំផុតចាប់ផ្តើមទទួលស្គាល់ពីផលប៉ះពាល់ចម្រុះដែលការធ្វើចំណាកស្រុកបង្កដោយប្រយោល មិនត្រឹមតែលើជនចំណាកស្រុកប៉ុណ្ណោះទេថែមទាំងលើកូនៗ របស់ពួកគេ សមាជិកគ្រួសារផ្សេងទៀត និងសហគមន៍ទូទៅផង។

# ផលប៉ះពាល់លើកុមារដែលត្រូវបានទុកចោល

អាយុហាក់បីដូចជាកត្តាសំខាន់ក្នុងការសម្រេចចិត្តថាតើត្រូវយកកុមារទៅតាមឬអត់ នៅពេលដែលឪពុកម្តាយសម្រេចចិត្តធ្វើចំណាកស្រុក។ កុមារតូចៗច្រើនតែត្រូវបានទុកចោល ខណៈពេលដែលកុមារអាយុលើស ១៥ ឆ្នាំ ច្រើនតែធ្វើដំណើរតាមឪពុកម្តាយ ឬសាច់ញាតិផ្សេងទៀត។ នេះអាចដោយសារតែអាយុអប្បបរមាសម្រាប់ធ្វើការងារក្នុងប្រទេសកម្ពុជាគឺ ១៥ ឆ្នាំ ដូច្នេះហើយបានជាកុមារអាយុលើស ១៥ ឆ្នាំភាគច្រើនធ្វើចំណាកស្រុកតាមឪពុកម្តាយ និងធ្វើការងារ។

## ជីដូនជីតា គឺជាអ្នកផ្តល់ការថែទាំចម្បងដល់កុមារដែលត្រូវបានទុកចោល

ការអង្កេតរបស់គម្រោង CRUMP រកឃើញថា ក្នុងចំណោមអ្នកធ្វើចំណាកស្រុកក្នុងប្រទេសដែលទុកកូនចោល ៨២,៤ ភាគរយទុកកូនឱ្យនៅជាមួយជីដូនជីតា។ លទ្ធផលរកឃើញនេះគឺស្រដៀងគ្នាជាមួយនឹងលទ្ធផលនៃការប្រមូលទិន្នន័យបឋម ដែលធ្វើឡើងដោយការស្រាវជ្រាវនេះដែរ ដោយក្នុងចំណោមអ្នកផ្តល់ការថែទាំ ២៧ នាក់ មាន ២១ នាក់ គឺជីដូនជីតា។

អាយុមធ្យមរបស់ជីដូនក្នុងការសិក្សានេះគឺ ៦២,៤ ឆ្នាំ ហើយពួកគេភាគច្រើនរស់នៅក្នុងកាលៈទេសៈលំបាក។

ស្ត្រីទាំងនេះភាគច្រើនមានការអប់រំតិចតួច ហើយស្ទើរតែពាក់កណ្តាលពុំបានរៀនសូត្រតែម្តង។ ជីដូនជីតាម្នាក់មើលថែចៅចន្លោះពី ១ ទៅ ៨ នាក់។

ជីដូនជីតាភាគច្រើនក្នុងការសិក្សានេះមានបញ្ហាសុខភាព និងបានរៀបរាប់ថាខ្លួនជួបការលំបាករៀងរាល់ថ្ងៃ ដោយសារតែបន្ទុកមើលថែចៅ។ ស្ត្រីវ័យចំណាស់ជាច្រើននាក់ពន្យល់ថា ពួកគាត់គ្មានជម្រើសអ្វីឡើយគឺត្រូវតែមើលថែចៅៗរបស់ខ្លួន។ ពួកគាត់ត្រូវបង្ខំចិត្តបំពេញតួនាទីនេះនៅដំណាក់កាលចុងក្រោយនៃជីវិតដោយសារតែកាលៈទេសៈតម្រូវដែលផុតដៃរបស់ពួកគាត់។ ជីដូនម្នាក់ពន្យល់ថា ជារឿយៗគាត់គិតថា គាត់មិនអាចថែទាំចៅៗឱ្យបានត្រឹមត្រូវឡើយ។ គាត់និយាយថា គាត់មានការនឿយហត់ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ក្នុងការមើលថែចៅៗ៖



## ការផ្ញើប្រាក់មកផ្ទះ

នៅពេលសាកសួរពីអត្ថប្រយោជន៍ទូទៅនៃការធ្វើចំណាកស្រុករបស់ឪពុកម្តាយលើកុមារ អ្នកផ្តល់ការថែទាំស្ទើរតែទាំងអស់លើកឡើងថា

> “មានលុយឱ្យកូនទៅរៀន ទិញសម្លៀកបំពាក់ និងទិញម្ហូបអាហារ” ឬ
>
> “ផ្ញើរលុយមកផ្ទះវិញ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ”

ជាអត្ថប្រយោជន៍ធំៗជាងគេ ដែលទាំងអស់នេះអាចធ្វើទៅបានដោយសារតែប្រាក់ដែលផ្ញើត្រលប់មកផ្ទះវិញ។

សមាជិកគ្រួសារភាគច្រើនដែលរស់នៅក្នុងភូមិប្រភពដើមពឹងអាស្រ័យខ្លាំងលើប្រាក់ផ្ញើមកនេះ។ អ្នកថែទាំភាគច្រើននៅតំបន់ជនបទដែលរាយការណ៍ថាបានទទួលប្រាក់ខ្លះពីសមាជិកគ្រួសារដែលធ្វើចំណាកស្រុក ប្រើប្រាស់លុយនេះសម្រាប់ចំណាយទូទៅជាពិសេសលើម្ហូបអាហារ (ឆ្លើយដោយអ្នកឆ្លើយសម្ភាសទាំងអស់)។

អ្នកផ្តល់ការថែទាំស្ទើរតែទាំងអស់លើកឡើងថា ជីវភាពជារួមមានកម្រិតខ្ពស់ជាងមុន ក្រោយពេលមានសមាជិកណាម្នាក់ក្នុងគ្រួសាររបស់ពួកគេធ្វើចំណាកស្រុក មិនថាធ្វើចំណាកស្រុកទៅទីណានោះទេ។ ការសម្ភាសជាមួយកុមារបានបង្ហាញថា របបអាហាររបស់ពួកគេមានភាពល្អប្រសើរជាងមុន ក្រោយពេលមានការធ្វើចំណាកស្រុក មិនថាពួកគេត្រូវបានទុកចោល ឬធ្វើចំណាកស្រុកតាមគ្រួសារ ឬធ្វើចំណាកស្រុកតែឯងនោះទេ។ ចំនួនអាហារទទួលទានក្នុងមួយថ្ងៃ ឬគុណភាព និងភាពចម្រុះមុខរបស់អាហារមានការកើនឡើង ហើយក្នុងករណីមួយចំនួន គឺកើនឡើងទាំងពីរតែម្តង។ ក្នុងករណីភាគច្រើនដែលជាសំណាកគំរូក្នុងការស្រាវជ្រាវនេះ ប្រាក់ផ្ញើត្រលប់មកផ្ទះវិញគឺជាប្រភពចំណូលចម្បងសម្រាប់គ្រួសារទាំងមូល។

អ្នកឆ្លើយតបភាគច្រើន ក្នុងការសិក្សានេះបានលើកឡើងថា បានចំណាយប្រាក់ផ្ញើមកមួយភាគសម្រាប់គាំទ្រដល់ការអប់រំរបស់កុមារ។ ប៉ុន្តែនៅពេលដែលកុមារដល់អាយុ ១៥ ឆ្នាំ ប្រាក់ផ្ញើមកនេះច្រើនតែថយចំនួន ហើយឥទ្ធិពលដែលប្រាក់ផ្ញើមកមានលើការចូលរៀនក៏មានការថមថយផងដែរ។

ករណីសិក្សានានាបានរកឃើញថា គ្រួសារដែលមានតែជីដូនជីតាជាមេគ្រួសារនៅតែជួបការលំបាកក្នុងការផ្តល់អាហារដល់កុមារឱ្យបានជាប់លាប់។ ជីដូនជីតាទាំងអស់ក្នុងករណីសិក្សាទាំងនេះបានលើកឡើងថា ពេលខ្លះពួកគេត្រូវបង្ខំចិត្តញ៉ាំតែបាយប៉ុណ្ណោះពេញមួយថ្ងៃ ហើយត្រូវខ្ចីអង្ករមកដាំបាយឱ្យចៅៗញ៉ាំបើទោះបីជាក្រោយពេលមានសមាជិកគ្រួសារធ្វើចំណាកស្រុកក៏ដោយ។ ការស្រាវជ្រាវបឋមបានរកឃើញមានជីដូនជីតាដែលពុំបានទទួលការផ្ញើប្រាក់ ហើយពុំមានប្រភពចំណូលជាប់លាប់ផ្សេងទៀត។ ក្នុងខេត្តសៀមរាប ជីដូនអាយុ ៦១ ឆ្នាំម្នាក់ ត្រូវទុកចៅអាយុ ៨ និង ១០ ឆ្នាំ ចោលម្តង ៤ ទៅ ៥ ថ្ងៃ ដើម្បីទៅសុំទានគេ ចាប់តាំងពីពេលដែលកូនស្រីរបស់គាត់ដែលធ្វើចំណាកស្រុកទៅប្រទេសថៃលែងផ្ញើប្រាក់មកក្រោយពេលដែលនាងបានរៀបការជាមួយប្តីក្រោយ។

ការពុំមានប្រព័ន្ធគាំពារសង្គមក្នុងប្រទេសមានន័យថា ពុំមានសំណាញ់សុវត្ថិភាពសង្គមផ្លូវការដែលជីដូនជីតាទាំងនេះអាចពឹងពំនាក់បានឡើយ។

## ការទទួលបានការអប់រំ និងការបន្តការអប់រំ

ការសិក្សាមួយដែលធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) អំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកលើកុមារដែលត្រូវបានគេទុកចោលបានរកឃើញថា ការធ្វើចំណាកស្រុកចេញក្រៅរបស់មនុស្សពេញវ័យមានផលប៉ះពាល់អវិជ្ជមានលើការរៀនសូត្ររបស់កុមារ (CDRI, 2014)។ កុមារក្នុងគ្រួសារចំណាកស្រុកច្រើនតែបោះបង់ចោលការសិក្សា ជាពិសេសកុមារីដោយហេតុថា ពួកគេត្រូវរួមចំណែកធ្វើការងារផ្ទះ និងរកចំណូលជួយគ្រួសារ ឬមានចំណាប់អារម្មណ៍តិចតួចលើការរៀនសូត្រ។ ប៉ុន្តែលទ្ធផលរកឃើញសម្រាប់កុមារដែលត្រូវបានគេទុកចោលក្នុងការសិក្សានេះបង្ហាញថាកុមារអាយុចូលរៀនភាគច្រើនក្នុងគ្រួសារចំណាកស្រុកបានចុះឈ្មោះចូលរៀន និងពុំមានការរាយការណ៍ពីបញ្ហាពាក់ព័ន្ធនឹងការទៅរៀនទៀងទាត់ឡើយ បើទោះបីជាពួកគេត្រូវជួយជីដូនជីតារបស់ពួកគេធ្វើការងារផ្ទះ ឬការងារស្រែចំការក៏ដោយ។ ជារួម ការស្រាវជ្រាវបឋមពុំបានបង្ហាញពីបញ្ហាធំដុំពាក់ព័ន្ធជាមួយនឹងការបន្តទទួលបានការអប់រំសម្រាប់កុមារដែលត្រូវបានគេទុកចោលឡើយ។

អ្នកផ្តល់ការថែទាំដល់កុមារមួយចំនួន រាយការណ៍ថា លទ្ធផលសិក្សារបស់កុមារកាន់តែល្អប្រសើរជាងមុនក្រោយពេលដែលឪពុកម្តាយរបស់ពួកគេធ្វើចំណាកស្រុក ប៉ុន្តែមិនអាចពន្យល់ពីមូលហេតុបានឡើយ។ នេះអាចបង្ហាញថា ចំណូលបន្ថែមពីប្រាក់ដែលផ្ញើមកនេះបានជួយឱ្យកុមារបន្តរៀនសូត្រ ប៉ុន្តែចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀតត្រង់ចំណុចនេះដើម្បីទាញនូវសេចក្តីសន្និដ្ឋានដែលមានភស្តុតាងជាមូលដ្ឋាន។

## កិច្ចការពារកុមារ

ទាំងកុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយរបស់ពួកគេ ទាំងកុមារដែលឪពុកម្តាយធ្វើចំណាកស្រុកចោល សុទ្ធតែជួបប្រទះនឹងការគំរាមកំហែងចំពោះសុវត្ថិភាពរបស់ពួកគេ។ ការព្រួយបារម្ភដែលកើតមានជាទូទៅជាងគេសម្រាប់ក្រុមទាំងពីរគឺរយៈពេលដែលកុមារចំណាយដោយពុំមានការឃុំគ្រងពីមនុស្សពេញវ័យ។ ឪពុកម្តាយ ឬជីដូនជីតាស្ទើរតែទាំងអស់ក្នុងការស្រាវជ្រាវនេះបានលើកឡើងថាបានទុកកូនរបស់ខ្លួនចោលមួយរយៈពេលណាមួយ។

ក្នុងការសម្ភាសក្រុមប្រឹក្សាឃុំបានលើកនូវរឿងរ៉ាវជាឧទាហរណ៍ជាច្រើនអំពីកុមារដែលត្រូវបានគេបំពារបំពានផ្លូវភេទ និងផ្លូវកាយក្រោយពេលទុកឱ្យនៅជាមួយសាច់ញាតិ នៅពេលដែលឪពុកម្តាយរបស់ពួកគេធ្វើចំណាកស្រុក។ គ្រួសារ និងកុមារដែលធ្វើចំណាកស្រុកពុំបានលើកឡើងពីការបំពានលើកុមារឡើយ ហើយកង្វះប្រព័ន្ធទិន្នន័យនៅថ្នាក់ជាតិសម្រាប់កត់ត្រាករណីរំលោភបំពានលើកុមារធ្វើឱ្យកុមារជួបការលំបាក ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីប្រេវ៉ាឡង់នៃករណីដែលត្រូវបានរាយការណ៍ទាំងនេះ។

កុមារអាយុតិចបំផុតដល់ ២ ឆ្នាំ ត្រូវបានទុកឱ្យនៅតែឯង ក្នុងករណីមួយចំនួន ត្រូវបានគេទុកឱ្យនៅតែឯងយូរ។ ជីដូនជាច្រើននាក់ទុកចៅរបស់ខ្លួនច្រើនថ្ងៃ និងអាចមានទាំងច្រើនសប្តាហ៍ទៀត។ ឪពុកម្តាយ និងជីដូនជីតាភាគច្រើនដឹងថាវាមានគ្រោះថ្នាក់សម្រាប់កុមារ ជាពិសេសក្មេងដែលទើបដែលនឹងចេះដើរតេសតាស នៅពេលដែលពួកគេត្រូវបានគេទុកចោលបែបនេះ ប៉ុន្តែពួកគេបានពន្យល់ថា ពួកគេធ្វើបែបនេះ នៅពេលដែលពួកគេមិនអាចរកអ្នកជិតខាងណាម្នាក់ឱ្យមកជួយមើលកុមារទាំងនេះបាន។

ទារកដ្ឋានថែទាំកុមារមិនឃើញមានច្រើនឡើយ ហើយបើមាន គឺមាននៅតាមតំបន់ក្រុង និងគិតថ្លៃសេវាថ្លៃ។

ខណៈពេលដែលកុមារភាគច្រើន ដែលចូលរួមក្នុងការប្រមូលទិន្នន័យបឋមនេះ ពុំបានរាយការណ៍ពីការកើនឡើងនូវការធ្វើពលកម្មដោយសារតែការធ្វើចំណាកស្រុករបស់ឪពុកម្តាយ មានឧទាហរណ៍ជាច្រើនដែលបង្ហាញពីកុមារដែលធ្វើការងារ ភាគច្រើនជាអ្នកស៊ីឈ្នួលគេក្នុងវិស័យកសិកម្ម។

## សុខុមាលភាពផ្លូវអារម្មណ៍ និងផ្លូវចិត្ត

ការស្រាវជ្រាវនេះបានរកឃើញថា កុមារទទួលរងផលប៉ះពាល់អវិជ្ជមានខាងផ្លូវអារម្មណ៍ និងផ្លូវចិត្តជាច្រើន ដោយសារតែការធ្វើចំណាកស្រុក ដូចជាការរំខានដល់ទំនាក់ទំនងរវាងឪពុកម្ដាយ និងកូនជាដើម។ គ្រួសារភាគច្រើនដែលចូលរួមក្នុងការស្រាវជ្រាវនេះ មកលេងផ្ទះតែម្ដងប៉ុណ្ណោះក្នុងមួយឆ្នាំ ដោយសារតែការចាយវាយលើការធ្វើដំណើរ។ ជីដូនម្នាក់និយាយថា ចៅរបស់គាត់រស់នៅក្រៀមក្រំរហូតដោយសារតែនាងនឹកម្ដាយ។ បញ្ហាមួយទៀតគឺអារម្មណ៍អន្ទះអន្ទែងរបស់គ្រួសារជនចំណាកស្រុកទៅក្រៅប្រទេស។ ជីដូនជីតាដែលជាអ្នកមើលថែចៅ និងកូនរបស់ជនចំណាកស្រុកទៅក្រៅប្រទេសបានរៀបរាប់ថាខ្លួនរស់នៅជាមួយនឹងអារម្មណ៍អន្ទះអន្ទែងគ្រប់ពេល។ ជីដូនម្នាក់ដែលមើលថែចៅបាននិយាយថា៖



> “ម្ដាយរបស់ពួកគេយំ នៅពេលដែលនាងមកផ្ទះ ពួកគេទាំងពីរនាក់យំ ហើយកូនៗសុំឱ្យនាងនៅ ប៉ុន្តែនាងមិនអាចនៅបាន ដោយសារតែគ្រួសារយើងក្រ។ យើងគ្មានជម្រើសអ្វីនោះទេ។”

# ផលប៉ះពាល់លើកុមារដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយ

ការសិក្សានេះបានរកឃើញថា កុមារអាយុច្រើន ច្រើនធ្វើចំណាកស្រុកទៅជាមួយឪពុកម្តាយ។ ផលប៉ះពាល់លើសុខុមាលភាពរបស់កុមារដែលធ្វើចំណាកស្រុកទៅជាមួយឪពុកម្តាយ គឺខុសពីកុមារដែលទុកចោលក្នុងភូមិ។ សម្រាប់កុមារដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយ បញ្ហាធំជាងគេរកឃើញក្នុងការសិក្សានេះគឺការបន្តរៀនសូត្រ បញ្ហាការពារកុមារ នឹងពលកម្មកុមារផងដែរ។

## ការទទួលបានការអប់រំ និងការបន្តការសិក្សា

ទំនាក់ទំនងរវាងការធ្វើចំណាកស្រុករបស់ឪពុកម្តាយ និងកុមារ និងការសិក្សាបាននិងកំពុងទទួលបានការយកចិត្តទុកដាក់ពិសេសក្នុងប្រទេសកម្ពុជា និងក្នុងប្រទេសផ្សេងទៀតក្នុងតំបន់ ដោយសារតែការកើនឡើងនូវនិន្នាការនៃការធ្វើចំណាកស្រុក។

ការសិក្សាថ្មីមួយអំពីករណីបោះបង់ចោលការសិក្សានៅសាលាមធ្យមសិក្សាបឋមភូមិ (ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ ២០១៥) លើកឡើងថា ការធ្វើចំណាកស្រុកគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុនានា ដែលធ្វើឱ្យកុមារបោះបង់ចោលការសិក្សា។

ឯកសារទំនងជារបាំងដ៏ធំមួយសម្រាប់ឪពុកម្តាយមួយចំនួនក្នុងការចុះឈ្មោះកូននៅសាលារៀនថ្មី នៅពេលដែលពួកគេផ្លាស់ទៅទីនោះ។ បើទោះបីជាការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សាផ្តល់ដោយមិនគិតថ្លៃក្នុងប្រទេសកម្ពុជាក៏ដោយ គ្រួសារអ្នកធ្វើចំណាកស្រុកនៅតែជួបនឹងបញ្ហាប្រឈមនៅពេលដែលពួកគេចុះឈ្មោះកូនៗរបស់ពួកគេឱ្យចូលរៀននៅកន្លែងថ្មី។

ខណៈពេលដែលការចុះឈ្មោះចូលរៀនជាផ្លូវការបើកទទួលកុមារ នៅគ្រប់ទីតាំងទាំងអស់ក្នុងប្រទេស គេត្រូវការសំបុត្រកំណើតដើម្បីអាចចុះឈ្មោះបាន។ សំបុត្រកំណើតទំនងហាក់ដូចជាតម្រូវការដ៏តឹងរឹងសំរាប់ការចុះឈ្មោះចូលរៀន ។ តម្រូវការសំបុត្រកំណើត ហាក់ដូចជាមានសារសំខាន់២ ទីមួយគឺសំដៅជួយក្នុងការសំរេចចិត្តដាក់សិស្សឱ្យចូលកំរិតថ្នាក់ត្រូវតាមអាយុទី២ គឺដើម្បីជួយជំរុញការចុះសំបុត្រកំណើត។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តន៍ជាក់ស្តែងតម្រូវការសំបុត្រកំណើតបានក្លាយជាឧបសគ្គធំសំរាប់គ្រួសារធ្វើចំណាកស្រុកមួយចំនួនក្នុងការចុះឈ្មោះកូននៅសាលារៀន។

ការសិក្សាបានរកឃើញថាការផ្ទេរការសិក្សាមកទីប្រជុំជនជួបការលំបាកជាពិសេសការផ្ទេរចូលសាលាភ្នំពេញ ដោយសារត្រូវចំណាយក្រៅផ្លូវការក្នុងបរិមាណខ្ពស់គួរឱ្យកត់សំគាល់។ ទោះបីមានសំបុត្រកំណើតហើយក៏ដោយដំណើរការផ្ទេរសាលាអាចត្រូវការពេលវេលាយូរ និងមានភាពស្មុគស្មាញ។ អ្នកឆ្លើយតបមួយចំនួនបានឱ្យដឹងថា ពួកគេបានបង់ប្រាក់ក្រៅផ្លូវការក្នុងចំនួនច្រើនគួរសមដើម្បីទទួលបានការសម្របសម្រួលក្នុងការផ្ទេរការសិក្សារបស់កូនមកសិក្សានៅភ្នំពេញ។

បើតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ ២០១៤ មានកុមារតែ ៦៤ ភាគរយប៉ុណ្ណោះ ដែលមានសំបុត្រកំណើត។ នេះធ្វើឱ្យមានបញ្ហាជាច្រើនសម្រាប់ប្រជាជនកម្ពុជាដែលរស់នៅតាមតំបន់ជនបទដែលមិនដឹងពីលក្ខខណ្ឌតម្រូវបែបនេះ ឬដែលមិនបានចុះសំបុត្រកំណើតឱ្យកូន ដោយសារមូលហេតុផ្សេងទៀត។ ឧទាហរណ៍ ក្មេងស្រីអាយុ ១២ ឆ្នាំម្នាក់ មិនអាចទៅសាលារៀនបាននៅពេលដែលនាងផ្លាស់មកទីក្រុងភ្នំពេញ ជាមួយនឹងគ្រួសាររបស់នាង៖

> “ខ្ញុំអត់បានទៅរៀនទេ នៅពេលនេះ ដោយសារតែខ្ញុំបាត់សំបុត្រកំណើតរបស់ខ្ញុំ ដូច្នេះសាលារៀនមិនទទួលខ្ញុំឡើយ។ ឪពុកម្តាយរបស់ខ្ញុំត្រលប់ទៅភូមិវិញ ដើម្បីចុះសំបុត្រកំណើតថ្មីឱ្យខ្ញុំ ប៉ុន្តែនៅពេលដែលយើងយកមកដាក់នៅសាលារៀន ក្នុងទីក្រុងភ្នំពេញ គេនៅតែមិនទទួលយកខ្ញុំ។ ពួកគេនិយាយថា ពួកគេចង់បានសំបុត្រកំណើតចាស់ ហើយពួកគេនិយាយថា ខ្ញុំអាយុច្រើនពេកមិនអាចចុះឈ្មោះបាន។ ឥលូវនេះខ្ញុំអាយុ ១២ ឆ្នាំហើយ។”

បញ្ហាប្រឈមមិនរំពឹងទុកមួយទៀតដែលគ្រួសារក្រីក្រមួយចំនួនជួបប្រទះ ក្រោយពេលចុះឈ្មោះកូនចូលរៀនក្នុងសាលារៀនក្នុងទីក្រុងភ្នំពេញគឺចំណាយខ្ពស់លើការបង់ថ្លៃសាលារៀនក្រៅផ្លូវការ។ ថ្លៃសាលារៀនក្រៅផ្លូវការ គឺជាប្រាក់បង់ប្រចាំថ្ងៃ ដែលកុមារត្រូវបង់ឱ្យគ្រូជាការបំពេញបន្ថែមពីលើបៀវត្សរ៍ដ៏តិចតួចរបស់គ្រូ។ ក្នុងករណីជាច្រើន កុមារដែលពុំមានលទ្ធភាពបង់ថ្លៃបែបនេះនឹងត្រូវគេធ្វើឱ្យអាម៉ាសមុខ ហាមឃាត់មិនឱ្យចូលរួមពេញលេញក្នុងថ្នាក់រៀន ឬមិនអាចប្រលងជាប់ដើម្បីឡើងថ្នាក់ (Brehm et al., 2012)។

ដោយឡែក កុមារដែលធ្វើចំណាកស្រុកទៅប្រទេសថៃជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនក្នុងការទទួលបានការអប់រំ។

បញ្ហាប្រឈមទាំងនេះ រួមមាន ឧបសគ្គខាងភាសាកង្វះឯកសារត្រឹមត្រូវ ភាពចាំបាច់ក្នុងការរកចំណូល និងការប្រែប្រួលនៃរយៈពេលស្នាក់នៅ។ អ្នកចូលរួមម្នាក់ក្នុងករណីសិក្សាគឺជាកុមារអាយុ ៨ ឆ្នាំ ដែលតាមឪពុកម្តាយនាងទៅប្រទេសថៃ។ នាងមិនបានទៅរៀនឡើយ ពេលដែលនាងនៅប្រទេសថៃ។ ជីដូនរបស់នាងពន្យល់ថា៖

> “នាងមិនបានទៅរៀន នៅប្រទេសថៃឡើយ ដោយសារតែឪពុកម្តាយរបស់នាងរស់នៅទីនោះខុសច្បាប់។ គេឱ្យនាងទៅ ប៉ុន្តែឪពុកម្តាយរបស់នាងទៅខុសច្បាប់ ពួកគេខ្លាចប៉ូលីសចាប់។
>
> ពួកគេខ្លាចមានគេចាប់ជម្រិតនាង ឬយកនាងទៅបាត់ នៅពេលដែលនាងនៅសាលារៀន ហើយពួកគេនឹងមិនអាចយកនាងមកវិញបានឡើយដោយសារតែពួកគេខុសច្បាប់។”



ការបន្តការសិក្សាក្រោយពេលធ្វើចំណាកស្រុកទៅតំបន់ទីក្រុងក៏ជួបនឹងការលំបាកផងដែរ ជាពិសេសកុមារដែលមានអាយុច្រើន (១៥-១៨ឆ្នាំ)។ កុមារក្នុងក្រុមអាយុនេះត្រូវបានចាត់ទុកថាសមស្របសម្រាប់ធ្វើការងារពេញម៉ោង ជាពិសេសសម្រាប់គ្រួសារក្រីក្រ ដែលការអប់រំមានចំណាយឱកាសខ្ពស់ខ្លាំង។ ក្នុងបរិបទនេះ ឱកាសសេដ្ឋកិច្ចដែលមានក្នុងទីក្រុង ជាពិសេសទីក្រុងភ្នំពេញ អាចមានឥទ្ធិពលដោយប្រយោលធ្វើឱ្យកុមារក្នុងក្រុមអាយុនេះបោះបង់ចោលការសិក្សាដើម្បីធ្វើដំណើររកការងារធ្វើ។ ក្នុងករណីមួយចំនួន កុមារសម្រេចចិត្តធ្វើចំណាកស្រុកតែឯងដែលធ្វើឱ្យពួកគេកាន់តែប្រឈមនឹងការកេងប្រវ័ញ្ច និងគ្រោះថ្នាក់ផ្សេងៗ។

ឧទាហរណ៍ ក្មេងស្រីអាយុពី ១៥ ដល់ ១៦ ឆ្នាំ ជាច្រើននាក់ ដែលត្រូវបានសម្ភាសក្នុងទីក្រុងភ្នំពេញ បាននិយាយថា ពួកគេបោះបង់ចោលការសិក្សានៅភូមិកំណើតរបស់ពួកគេ ដោយសារតែពួកគេឮពីឱកាសការងារតាមរោងចក្រកាត់ដេរ ក្នុងទីក្រុងភ្នំពេញ។ បើទោះបីជាឪពុកម្តាយរបស់ពួកគេមិនយល់ស្របតាមការសម្រេចចិត្តរបស់ពួកគេក៏ដោយ ពួកគេសម្រេចចិត្តទៅ ដើម្បីជួយសម្រាលបន្ទុកស្ថានភាពសេដ្ឋកិច្ចយ៉ាប់យ៉ឺននៃគ្រួសាររបស់ពួកគេ។ កម្មការនីរោងចក្រកាត់ដេរវ័យ ១៦ ឆ្នាំម្នាក់ បានពន្យល់ថា៖

> “គ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រ។ ឪពុកម្តាយរបស់ខ្ញុំឧបត្ថម្ភដល់ការសិក្សារបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចទ្រាំឃើញពួកគាត់ធ្វើការនឿយហត់ខ្លាំង ដើម្បីរ៉ាប់រងចំណាយ [អ្វីៗគ្រប់យ៉ាង]ឡើយ។ ដូច្នេះ ខ្ញុំសម្រេចចិត្តឈប់រៀន និងធ្វើចំណាកស្រុក ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំមិនដឹងឡើយ។ ថ្ងៃមួយនោះ ពួកគាត់ទៅស្រែ ហើយខ្ញុំបានចាកចេញមកភ្នំពេញ ដោយមិនបានប្រាប់ពួកគាត់ឡើយ។ ពួកគាត់ខឹងនឹងខ្ញុំយ៉ាងខ្លាំង ប៉ុន្តែខ្ញុំមិនអាចឃើញពួកគាត់ស្ថិតក្នុងស្ថានភាព [ពិបាកខាងលុយកាក់] បែបនោះឡើយ។”

## ពលកម្មកុមារ និងសុវត្ថិភាពផ្លូវកាយ

កុមារអាយុច្រើន ដែលត្រូវបានសម្ភាសក្នុងការសិក្សានេះ ជាអ្នកធ្វើការងារសំណង់ ដែលត្រូវបានចាត់ទុកថាជាការងារគ្រោះថ្នាក់ ដោយសារតែកម្រិតហានិភ័យ និងសម្ភារដែលប្រើប្រាស់ក្នុងការងារនេះ (NIS, 2013b)។

ការព្រួយបារម្ភមួយទៀត គឺសុវត្ថិភាពនៃបរិស្ថានរស់នៅរបស់កុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយរបស់ពួកគេ។ កុមារមួយចំនួន ដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយ ឬធ្វើចំណាកស្រុកតែឯង ត្រូវរស់នៅតាមការដ្ឋានសំណង់។ ការអង្កេតលើពលកម្មកុមាររបស់ ILO ឆ្នាំ ២០១២ បានរកឃើញថា កន្លែងធ្វើការសំខាន់ជាងគេ សម្រាប់ពលកម្មកុមារជាក្មេងប្រុស ៨២,១ ភាគរយ និងក្មេងស្រី ១៧,៩ ភាគរយ គឺការដ្ឋានសំណង់ (ILO, 2013)។ កុមារដែលត្រូវបានសម្ភាសសម្រាប់ការសិក្សានេះ រមែងរស់នៅតាមការដ្ឋានសំណង់ ដែលមានបរិស្ថានប្រកបដោយគ្រោះថ្នាក់ ដោយសារតែសកម្មភាពសាងសង់ផង និងដោយសារតែការប្រឈមនឹងធូលី និងសម្ភារនានាផង។

ការសិក្សានេះសង្កេតឃើញថា កុមារដែលធ្វើដំណើរទៅប្រទេសថៃ ក្នុងនាមជាជនចំណាកស្រុកខុសច្បាប់ ជាអ្នកដែលប្រឈមនឹងផលប៉ះពាល់អវិជ្ជមានជាងគេខាងសុវត្ថិភាព។ ជនចំណាកស្រុកភាគច្រើនដែលចូលទៅប្រទេសថៃពីប្រទេសកម្ពុជាចូលទៅប្រទេសថៃដោយពុំបានបំពេញបែបបទអន្តោប្រវេសន៍ត្រឹមត្រូវឡើយ ហើយត្រូវបានរដ្ឋាភិបាលថៃចាត់ទុកថាជាអ្នករស់នៅខុសច្បាប់ ទាំងមនុស្សពេញវ័យ ទាំងកុមារបានរៀបរាប់ថា ពួកគេមានការភ័យខ្លាចតម្រួតថៃជាប្រចាំ។ កុមារម្នាក់និយាយថា៖

> “ខ្ញុំទៅធ្វើការងារក្នុងប្រទេសថៃ ជាមួយនឹងជីដូនរបស់ខ្ញុំ។ គាត់លក់ខ្ទឹមតាមផ្លូវ។ នៅពេលដែលខ្ញុំទៅដើរលេង តម្រួតថៃចាប់ខ្ញុំ ហើយបញ្ជូនខ្ញុំមកប្រទេសកម្ពុជាវិញ។ ខ្ញុំមកវិញ ៦ ខែហើយ ប៉ុន្តែជីដូនរបស់ខ្ញុំមិនទាន់បានត្រលប់មកវិញទេឡើយ។ ”

របាយការណ៍ពីអ្នកពាក់ព័ន្ធនានាដែលធ្វើការងារជាមួយកុមារខ្មែរក្នុងប្រទេសថៃ គួបផ្សំនឹងលទ្ធផលរកឃើញពីការសិក្សាពាក់ព័ន្ធនានាផងបង្ហាញថា ការសុំទានតាមផ្លូវ ជាពិសេសពេលយប់ធ្វើឱ្យកុមារត្រូវប្រឈមនឹងហានិភ័យ។ ពួកគេក៏បានលើកឡើងផងដែរថា កុមារដែលត្រូវបានគេបង្ខំឱ្យសុំទានជាក្រុមដោយមានអ្នកចាត់ចែងពីក្រោយ និងឱ្យប្រាក់ដែលរកបានទៅមនុស្សពេញវ័យត្រូវបានចាត់ទុកថាជាកុមារដែលត្រូវបានជួញដូរ(Friends, 2006)។

កុមារដែលវិលត្រលប់មកពីប្រទេសថៃវិញ និងអ្នកពាក់ព័ន្ធនានាដែលធ្វើការងារនៅសងខាងព្រំដែនបានរៀបរាប់ពីនីតិវិធីសម្រាប់បញ្ជូនកុមារត្រលប់មកប្រទេសកម្ពុជាវិញ ក្រោយពេលចាប់ខ្លួនដោយតម្រួតថៃ។ លក្ខខណ្ឌ និងនីតិវិធីទាំងនេះធ្វើឱ្យមានការព្រួយបារម្ភ។ កុមារភាគច្រើននាក់ត្រូវបានបំបែកពីឪពុកម្ដាយរបស់ពួកគេ ដោយសារតែពេលចាប់ខ្លួនកុមារទាំងនោះនៅតែឯង។

កុមារមួយចំនួនត្រូវបានបញ្ជូនត្រលប់មកប្រទេសកម្ពុជាភ្លាម ប៉ុន្តែកុមារជាច្រើននាក់ត្រូវបានទុកក្នុងមណ្ឌលក្នុងរយៈពេលយូរចាប់ពី ៨ ខែ រហូតដល់ជាង ១ ឆ្នាំ។ មណ្ឌលឃុំកុមារទុកប្រឆាំងនឹងបំណងកុមារ ហើយលក្ខខណ្ឌរស់នៅក្នុងមណ្ឌលទាំងនោះគឺមានលក្ខណៈអន់ថយ។ មណ្ឌលមួយក្នុងចំណោមមណ្ឌលក្នុងប្រទេសថៃទាំងនេះក៏ជាកន្លែងទុកជនអនាថាជាមនុស្សពេញវ័យផងដែរ។ អ្នកផ្ដល់ព័ត៌មានសំខាន់ម្នាក់ ដែលធ្វើការងារក្នុងមណ្ឌលនេះបានពន្យល់ថា បុគ្គលិកនៅទីនេះចាត់ទុកការងាររបស់ពួកគេថាជាអ្នកត្រួតពិនិត្យកុមារ មិនមែនជាអ្នកមើលថែកុមារនោះទេ។ គាត់ពន្យល់ថា ពុំមានមណ្ឌលណាដែលមានគោលនយោបាយស្ដីពីកិច្ចការពារកុមារឡើយ ហើយគាត់ធ្លាប់ឃើញបុគ្គលិកបំពារបំពានផ្លូវកាយ និងផ្លូវភេទលើកុមារជាច្រើនលើកច្រើនសារ។

កុមារជាច្រើននាក់ដែលត្រូវបានបញ្ជូនមកប្រទេសកម្ពុជាវិញ បន្ទាប់ចាប់ខ្លួនដោយអាជ្ញាធរថៃរួច ដំបូងត្រូវបានឃុំខ្លួនក្នុងប្រទេសថៃសិន ហើយបន្ទាប់មកបញ្ជូនតាមមណ្ឌលសំចតនៅប៉ោយប៉ែត។ បន្ទាប់មកកុមារមួយចំនួនក្នុងចំណោមកុមារទាំងនេះត្រូវបានគេនាំទៅដាក់ក្នុងមណ្ឌលថែទាំកុមារនៅប៉ោយប៉ែតដែលនៅទីនេះមានការខិតខំជួយរកឪពុកម្ដាយរបស់កុមារទាំងនេះ។

នេះអាចជាដំណើរការមួយដ៏ពិបាក ដោយហេតុថាពុំមានយន្តការផ្លូវការរបស់រដ្ឋាភិបាលដើម្បីជួយឱ្យកុមារ និងឪពុកម្ដាយដែលបែកគ្នាអាចជួបជុំគ្នាវិញបានឡើយ។ ប្រសិនបើគេរកមិនឃើញឪពុកម្ដាយ ឬ អាណាព្យាបាលសម្រេចចិត្តមិនត្រលប់មកប្រទេសកម្ពុជាវិញ កុមារអាចរស់នៅក្នុងមណ្ឌលកុមារជាអចិន្ត្រៃយ៍ តែបើរកឪពុកម្ដាយឃើញបុគ្គលិកក្នុងមណ្ឌលថែទាំនេះបាននិយាយថា កុមារភាគច្រើនធ្វើចំណាកស្រុកចូលទៅក្នុងប្រទេសថៃវិញសារជាថ្មីយ៉ាងឆាប់តាមតែពួកគេអាចទៅបាន។

# សេវាដែលមានសម្រាប់កុមារដែលរងផលប៉ះពាល់ដោយសារការធ្វើចំណាកស្រុក

## សេវាដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល

ទីក្រុងភ្នំពេញគឺជាទីបណ្តុំនៃសេវាផ្សេងៗច្រើនជាងគេដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ប៉ុន្តែការគ្របដណ្តប់នៃសេវាទាំងនេះកាន់តែខ្សត់ខ្សោយទៅនៅតំបន់កាន់តែឆ្ងាយពីរាជធានី។ មានមណ្ឌលសំចតតាមព្រំដែនចំនួន ២ នៅភូមិភាគពាយព្យនៃប្រទេសកម្ពុជាគឺ មណ្ឌលសំចតប៉ោយប៉ែត និងដំណាក់ទឹក។ មណ្ឌលទាំងនេះផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន ការថែទាំសុខភាព និងផ្លូវចិត្ត និងជំនួយផ្សេងទៀតដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងជនចំណាកស្រុកខុសច្បាប់ដែលវិលត្រលប់មកពីប្រទេសថៃវិញ រាប់បញ្ចូលទាំងកុមារដែលត្រឡប់មកតែឯងដោយគ្មានអ្នករួមដំណើរផង។ ប៉ុន្តែមណ្ឌលសំចតប៉ោយប៉ែតផ្តល់ការស្នាក់នៅតែមួយយប់ប៉ុណ្ណោះ ហើយមណ្ឌលសំចតដំណាក់ទឹកមានសមត្ថភាពតិចតួចហើយពេលខ្លះពុំមានលទ្ធភាពជួយគ្រប់កុមារទាំងអស់ដែលបញ្ជូនមកមណ្ឌលនេះឡើយ។ សេវាផ្សេងទៀត ដូចជាការផ្តល់ប្រឹក្សាច្បាប់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើមគឺមាននៅទីរួមខេត្ត។ ឧទាហរណ៍ មានផ្ទះស្នាក់នៅមួយក្នុងខេត្តសៀមរាបទទួលបានការគាំទ្រពីមជ្ឈមណ្ឌលកម្ពុជាសម្រាប់ការពារសិទ្ធិកុមារដែលទទួលក្មេងស្រីដែលមិនចង់ទៅ ឬមិនអាចវិលត្រលប់ទៅកាន់ភូមិកំណើតរបស់ពួកគេវិញឱ្យស្នាក់នៅ និងសាខាមួយរបស់អង្គការ Friends International ដែលផ្តល់នូវជម្រកសុវត្ថិភាព និងមណ្ឌលបណ្តុះបណ្តាល ក្នុងខេត្តសៀមរាប ជាការឆ្លើយតបចាប់តាំងពីខេត្តនេះក្លាយជាតំបន់គោលដៅធំមួយសម្រាប់ជនចំណាកស្រុកក្នុងប្រទេសក្នុងនោះមានទាំងកុមារផងដែរ។

# សេវារបស់រាជរដ្ឋាភិបាល

បន្ទាប់ពីករណីយោធាថៃបញ្ជូនពលករត្រលប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំផ្តល់សេវាឯកសារស្របច្បាប់សម្រាប់ដល់ពលករចំណាកស្រុកឆ្លងដែនដើម្បីឱ្យពួកគេអាចត្រលប់ទៅធ្វើការងារក្នុងប្រទេសថៃវិញ។

សេវាទាំងនេះរួមមានការផ្តល់លិខិតឆ្លងដែនក្នុងតម្លៃសមរម្យដោយកាត់បន្ថយពី ១២៤ ដុល្លារ ដល់ ៤ ដុល្លារ សម្រាប់លិខិតឆ្លងដែនមួយ និងរួមគ្នាបង្កើតកន្លែងត្រួតពិនិត្យតែមួយជាមួយនឹងសមភាគីថៃដើម្បីចេញអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតឱ្យធ្វើការងារដល់ពលករចំណាកស្រុក។

សម្រាប់ការធ្វើចំណាកស្រុកក្នុងប្រទេសពុំមានការផ្តល់សេវាដោយឡែករបស់រដ្ឋដល់ជនចំណាកស្រុក និងគ្រួសាររបស់ពួកគេនៅដំណាក់កាលណាមួយនៃការធ្វើចំណាកស្រុកឡើយ ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានទៀតក៏នៅមានកម្រិត។

អាជ្ញាធរភូមិក្នុងទីក្រុងបាននិយាយថា ជនចំណាកស្រុកផ្លាស់ទៅនៅក្នុងភូមិរបស់ពួកគេមិនមែនសុទ្ធតែមកចុះឈ្មោះ ឬបង្ហាញវត្តមានរបស់ពួកគេឡើយ។ ដូច្នេះអាជ្ញាធរមូលដ្ឋានមានការលំបាកក្នុងការប៉ាន់ប្រមាណពីចំនួនជនចំណាកស្រុកដែលចូលមកក្នុងសហគមន៍របស់ពួកគេ និងធ្វើការវាយតម្លៃពីប្រភេទសេវាដែលចាំបាច់។ នេះគឺជាឧបសគ្គធំមួយក្នុងការរៀបចំគោលនយោបាយ និងបែងចែកធនធានឱ្យបានគ្រប់គ្រាន់។ មេភូមិម្នាក់ក្នុងខេត្តសៀមរាបបាននិយាយថា៖

> “តួនាទីរបស់យើង គឺត្រូវផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ។ ប៉ុន្តែ ជនចំណាកស្រុកភាគច្រើនមិនបានរាយការណ៍ទៅមេភូមិ នៅស្រុកកំណើត ពីពេលវេលា ឬកន្លែងដែលពួកគេធ្វើចំណាកស្រុកឡើយ។ នៅពេលដែលពួកគេមករស់នៅទីនេះ ពួកគេមិនដែលរាយការណ៍ពីវត្តមានរបស់ពួកគេប្រាប់ខ្ញុំឡើយ។ ដូច្នេះ វាពិបាកនឹងធ្វើការងារជាមួយពួកគេណាស់។ យើងមិនអាចគ្រប់គ្រងពួកគេឡើយ។ យើងក៏ពុំមានទិន្នន័យច្បាស់លាស់ពីជនចំណាកស្រុកក្នុងតំបន់របស់យើងនោះដែរ។ ”

នៅថ្នាក់ភូមិ និងថ្នាក់ឃុំពុំមានសេវាសមាហរណកម្ម ឬការគាំទ្រសម្រាប់ជនចំណាកស្រុកដែលវិលត្រលប់មកវិញ ឬជនរងគ្រោះដោយសារការជួញដូរនោះទេ។ ក្រុមប្រឹក្សាឃុំសូម្បីតែក្នុងឃុំដែលមានអត្រាចំណាកស្រុកខ្ពស់ក៏ដោយ ពុំបានវិភាជន៍ថវិកាសម្រាប់ការងារនេះដែរ ហើយជាទូទៅពុំបានត្រៀមខ្លួនសម្រាប់ទទួលការវិលត្រលប់មកវិញរបស់ជនចំណាកស្រុកក្នុងអត្រាខ្ពស់ឡើយ។

ផ្អែកទៅតាមព័ត៌មានដែលទទួលបានពីការសម្ភាសជាមួយមេភូមិ និងមេឃុំ មានការទទួលខុសត្រូវធំៗចំនួន ២ ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណាកស្រុកដែលត្រូវបានធ្វើប្រតិភូកម្មដល់ពួកគេ៖

- ចុះចំនួនអ្នកដែលធ្វើចំណាកស្រុកចេញទៅតំបន់ផ្សេងទៀតជារៀងរាល់ឆ្នាំ (មូលដ្ឋានទិន្នន័យឃុំ)
- ផ្សព្វផ្សាយព័ត៌មានអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងស្របច្បាប់

# អនុសាសន៍

ផ្អែកទៅតាមលទ្ធផលរកឃើញ និងសេចក្តីសន្និដ្ឋានសំខាន់ៗដែលទទួលបានពីការស្រាវជ្រាវដែលមានការចុះប្រមូលព័ត៌មានផង និងពិនិត្យលើឯកសារពាក់ព័ន្ធផងនេះ ខាងក្រោមនេះគឺជាអនុសាសន៍ដែលត្រូវបានរៀបចំឡើងសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាសម្រាប់ទីភ្នាក់ងារសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

អនុសាសន៍សម្រាប់ស្ថាប័នរាជរដ្ឋាភិបាលដែលធ្វើការងារខាងគ្រប់គ្រងទេសន្តរប្រវេសន៍ និងបញ្ហាដែលពាក់ព័ន្ធនៅថ្នាក់ជាតិ ៖

## ការកែលម្អទិន្នន័យ៖

១. ក្រសួងផែនការគួរផ្តល់អាទិភាពដល់ការប្រមូល និងវិភាគទិន្នន័យនៅថ្នាក់ជាតិ អំពីជនចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ ក៏ដូចជាកូនៗរបស់ពួកគេដើម្បីផ្តល់ជាព័ត៌មានដល់ការរៀបចំគោលនយោបាយដូចជា៖

   - បន្ថែមសូចនាករលំអិតអំពីទេសន្តរប្រវេសន៍ទៅក្នុងមូលដ្ឋានទិន្នន័យឃុំ រាប់បញ្ចូលទាំងជនចំណាកស្រុកអាយុក្រោម ១៨ ឆ្នាំផង
   - ធ្វើការវិភាគអំពីកុមារដែលទុកចោលដោយជនចំណាកស្រុកក៏ដូចជាជនចំណាកស្រុកជាកុមារគ្រប់វ័យទាំងអស់ដោយប្រើប្រាស់សំណុំទិន្នន័យយកចេញពីជំរឿនប្រជាជនពេលអនាគត

- ធ្វើការអង្កេតជាក់លាក់ (specific household survey) ដើម្បីធ្វើការប៉ាន់ប្រមាណឱ្យបានកាន់តែប្រសើរអំពីចំនួនកុមារដែលត្រូវបានទុកចោល និងកុមារដែលធ្វើចំណាកស្រុក និងអំពីសុខុមាលភាពរបស់ពួកគេ

## កិច្ចគាំពារសង្គម និងសុខុមាលភាពសង្គមៈ

២. រាជរដ្ឋាភិបាលកម្ពុជាគួរពន្លឿនការពង្រីកវិសាលភាពនៃកិច្ចគាំពារសង្គមដោយផ្តោតលើគ្រួសារក្រីក្រ និងងាយរងគ្រោះ រួមនឹងមូលនិធិសមធម៌សុខាភិបាលផង ដើម្បីកាត់បន្ថយការជាប់បំណុលដោយសារការចំណាយខ្ពស់លើសេវាសុខភាព ដោយប្រើប្រាស់ប្រាក់ផ្ទាល់ខ្លួន និងកម្មវិធីផ្ទេរសាច់ប្រាក់។

៣. ក្រសួងផែនការធ្វើការពិនិត្យឡើងវិញលើការរៀបចំ និងនីតិវិធីនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) ដើម្បីធានាឱ្យបញ្ជីបច្ចុប្បន្នភាពនៃគ្រួសារក្រីក្រ និងប្រមូលព័ត៌មានអំពីប្រជាជនងាយរងគ្រោះដែលរស់នៅកៀកនឹងបន្ទាត់ក្រីក្រ។

៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរបង្កើនមន្ត្រីភ្នាក់ងារសង្គមកិច្ចឱ្យបានគ្រប់ចំនួន និងផ្តល់ធនធានឱ្យបានគ្រប់គ្រាន់សម្រាប់ស្រុក និងឃុំ ដើម្បីកំណត់រកកុមារងាយរងគ្រោះ រាប់បញ្ចូលទាំងកុមារដែលត្រូវបានទុកចោលដោយសារតែការធ្វើចំណាកស្រុករបស់ឪពុកម្តាយ និងបញ្ជូនពួកគេទៅរកសេវាពាក់ព័ន្ធនានា។

៥. ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធនានាដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពិនិត្យលើលទ្ធភាពផ្តល់សេវាទារកដ្ឋាន (ដោយមានឧបត្ថម្ភធន) សំរាប់បំរើដល់គ្រួសារចំណាកស្រុកក្នុងទីក្រុងដែលមានកូនតូច ដើម្បីធានាយ៉ាងណាមិនឱ្យមានការទុកកូនៗទាំងនេះចោលនៅពេលថ្ងៃពេលដែលឪពុកម្តាយទៅធ្វើការ។

## ការអប់រំៈ

៦. ក្រសួងអប់រំ យុវជន និងកីឡា គួរធានាយ៉ាងណាឱ្យសាលារៀនទាំងអស់ផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពយ៉ាងសុក្រិត្យអំពីនីតិវិធី និងលក្ខខណ្ឌសម្រាប់ចុះឈ្មោះសិស្ស (សំបុត្រកំណើត លិខិតបញ្ជាក់ពីការផ្ទេរសាលារៀន និងឯកសារពាក់ព័ន្ធផ្សេងទៀត) ដល់គ្រួសារចំណាកស្រុក។ ក្រសួងអប់រំ យុវជន និងកីឡា គួរបន្តប្រើប្រាស់គោលវិធីដែលមានភាពបត់បែន និងបន្តជួយសម្រួលជាពិសេសដើម្បីឱ្យសាលារៀនអាចចុះឈ្មោះកុមារចំណាកស្រុកបាន។

៧. ក្រសួងអប់រំ យុវជន និងកីឡាគួរបន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធ EMIS សម្រាប់ធ្វើការតាមដានទីតាំងរបស់សិស្សដើម្បីឱ្យគេអាចប្រមូលព័ត៌មានពីការធ្វើចំណាកស្រុកកុមារក្នុងប្រទេសកម្ពុជាបាន។

៨. ក្រសួងអប់រំ យុវជន និងកីឡាគួរពង្រឹងសេវាពិសេសសម្រាប់កុមារចំណាកស្រុកដែលមានអាយុច្រើន (១៥-១៨ ឆ្នាំ) ដែលច្រើនតែធ្វើដំណើរតែឯងដើម្បីរកការងារធ្វើ និងមិនបានរៀនសូត្រដោយបញ្ចូលទាំងកុមារដែលវិលត្រលប់ពីការធ្វើចំណាកស្រុកឆ្លងដែនផង។ សេវាទាំងនេះអាចមានជាថ្នាក់បង្រៀនពេលយប់ កម្មវិធីសិក្សាក្រៅម៉ោង កម្មវិធីពន្លឿនការសិក្សា ។ល។ ដើម្បីធានាយ៉ាងណាឱ្យក្មេងប្រុស និងក្មេងស្រីអាចរៀនចប់ការអប់រំជាមូលដ្ឋាន។

៩. ក្រសួងអប់រំ យុវជន និងកីឡាគួរបន្តកិច្ចខិតខំប្រឹងប្រែងធ្វើការវាយតម្លៃ និងផ្តល់ការទទួលស្គាល់ផ្លូវការដល់សាលារៀនតាមសហគមន៍ដែលបង្កើតឡើងក្នុងតំបន់របស់ជនចំណាកស្រុក។

អនុសាសន៍សម្រាប់ស្ថាប័នរាជរដ្ឋាភិបាលដែលធ្វើការងារខាងគ្រប់គ្រងទេសន្តរប្រវេសន៍និងបញ្ហាដែលពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ៖

១០. រដ្ឋបាលថ្នាក់ក្រោមជាតិ (គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ ឬស្ថាប័នផ្សេងទៀត) គួរបង្កើតយន្តការដើម្បីកំណត់រកគ្រួសារងាយរងគ្រោះ រួមនឹងកុមារដែលទុកចោលដោយឪពុកម្តាយធ្វើចំណាកស្រុក និងកុមារដែលធ្វើចំណាកស្រុកខ្លួនឯង និងពិនិត្យតាមដានសុខុមាលភាពកុមារ ផ្តល់ជំនួយសង្គម និងការគាំទ្រជាការការពារកុមារនៅពេលដែលចាំបាច់ ដោយប្រើប្រាស់មូលនិធិឃុំសង្កាត់ និងធនធានដែលមាន និងឬបញ្ជូនពួកគេទៅកាន់សេវាដែលផ្តល់ដោយស្ថាប័នរាជរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល។

## ទីភ្នាក់ងារសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលគួរៈ

១១. គាំទ្រដល់គំនិតផ្តួចផ្តើមស្រាវជ្រាវថ្មីៗ ដើម្បីបំពេញភាពខ្វះខាតចំណេះដឹងអំពីផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុក។

១២. គាំទ្រដល់ក្រុមប្រឹក្សាឃុំក្នុងកិច្ចខិតខំប្រឹងប្រែងកំណត់រកកុមារងាយរងគ្រោះ ពិនិត្យតាមដានសុខុមាលភាពរបស់ពួកគេក៏ដូចជាផ្តល់ជំនួយសង្គម និងការគាំទ្រជាការការពារកុមារ។

១៣. គាំទ្រជាការកសាងសមត្ថភាពដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់សេវាសុខុមាលភាពសង្គមនៅថ្នាក់មូលដ្ឋាន។

**បោះពុម្ពផ្សព្វផ្សាយដោយ:**
UNICEF Cambodia
អគារ Exchange Square ជាន់ទី៥
លេខ 19 & 20, ផ្លូវលេខ 106,
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានី ភ្នំពេញ

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក . ជ . ក.)**
លេខ #788 អគារ B ជាន់ទី 5
មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ

អ្នកនិពន្ធ: អូលហ្កា គ្រីមើ មៀ ចូដាន់វូដ និង សៅ សិដ្ឋកា (Emerging Markets Consulting Firm)
អ្នកកែសំរួល: លោកស្រី ដៀជ្រេ ស្មីត
អ្នកតាក់តែងរចនា: ក្រុមហ៊ុនក្រាហ្វិករូត
អ្នកថតរូប: លោក ខូយ បូណា
អ្នកគាំទ្របច្ចេទេស:
- លោកស្រី ម៉ាគី កាតូ (UNICEF)
- លោក ជា វិបុល (UNICEF)
- លោកជំទាវ ញ៉េប សុភាព (អគ្គលេខាធិការដ្ឋាន ក.ជ.ក)
- លោកជំទាវ ប៊ូ សោភ័ណ (អគ្គលេខាធិការដ្ឋាន ក.ជ.ក)
- លោក ភី ណូ (អគ្គលេខាធិការដ្ឋាន ក.ជ.ក)